ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៤៩ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត

- បង្កើត និងបង្កើនយន្តការនៃការវាយតម្លៃទីក្រុងស្អាតថ្នាក់ជាតិ និងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- ធានានូវការគ្រប់គ្រងវិស័យទេសចរណ៍ដោយឈរលើគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត** ចំណុះអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារវាយតម្លៃទីក្រុងស្អាតថ្នាក់ជាតិ និងទីក្រុងទេសចរណ៍ស្អាតអាស៊ាន។

**នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- ពិនិត្យ និងវាយតម្លៃទីក្រុងបេក្ខភាពស្របតាមស្តង់ដាទីក្រុងស្អាត
- រៀបចំ ជំរុញ ពិនិត្យ និងវាយតម្លៃទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំ អង្កេត និងវាយតម្លៃការអនុវត្តផែនការ និងគម្រោងអភិវឌ្ឍន៍ការងារប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- ពិនិត្យ និងលើកដំណោះស្រាយករណីមិនប្រក្រតីនៃការអនុវត្តរបស់ទីក្រុង ទីប្រជុំជន និងគោលដៅទេសចរណ៍ជ័យលាភី
- សិក្សាស្រាវជ្រាវ ប្រមូល ចងក្រង និងវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធនឹងការងារវាយតម្លៃទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំប្រព័ន្ធគ្រប់គ្រង និងបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត ទីប្រជុំជនស្អាត និងគោលដៅទេសចរណ៍ស្អាត
- រៀបចំផែនការសកម្មភាពកម្មវិធីអនុវត្តនានាទ្រទ្រង់ចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- សម្របសម្រួល និងធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិកអាស៊ានលើរាល់សកម្មភាពដែលទាក់ទងនឹងចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- សហការរៀបចំ និងវាយតម្លៃតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្ស និងគ្រប់ភាគីពាក់ព័ន្ធក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត និងចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត ដឹកនាំដោយប្រធាន **មួយ (០១) រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត មានការិយាល័យចំណុះចំនួន **០៦(ប្រាំមួយ)** ដូចខាងក្រោម៖

១-ការិយាល័យស្តង់ដាកិច្ចការស្រាវជ្រាវ និងស្ថិតិព័ត៌មាន

២-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ

៣-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគពាយ័ព្យ

៤-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគឦសាន្ត

៥-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគខាងត្បូង

៦-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងទេសចរណ៍ស្អាតអាស៊ាន។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធាន មួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានវាយតម្លៃទីក្រុងស្អាត ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗមានតួនាទី និងភារកិច្ចដូចតទៅៈ

**១-ការិយាល័យស្តង់ដា កិច្ចការស្រាវជ្រាវ និងស្ថិតិព័ត៌មាន** មានតួនាទី និងភារកិច្ចៈ

- ធ្វើបច្ចុប្បន្នកម្មលក្ខណៈវិនិច្ឆ័យសូចនាករលម្អិតសូចនាករគោលនិងស្តង់ដាទីក្រុងស្អាតស្របតាមរបត់អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងគោលការណ៍ណែនាំរបស់ថ្នាក់ដឹកនាំ
- ធ្វើបច្ចុប្បន្នកម្មឯកសារជំនួយគោលការណ៍ណែនាំសម្រាប់អនុវត្តស្តង់ដាទីក្រុងស្អាត
- ធ្វើបច្ចុប្បន្នកម្មនីតិវិធីប្រឡងប្រណាំងទីក្រុងស្អាត និងសេចក្តីណែនាំពាក់ព័ន្ធផ្សេងៗ
- ទទួលប្រមូលគ្រប់គ្រងលើពាក្យសុំនិងទិន្នន័យក្នុងពាក្យសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាតនិងបែកចែកទៅតាមការិយាល័យជំនាញរៀងៗខ្លួន
- បញ្ចូលរក្សាទុក និងធ្វើការវិភាគលើទិន្នន័យរបស់ក្រុង ខណ្ឌបេក្ខភាពដែលពាក់ព័ន្ធនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- សិក្សាស្រាវជ្រាវប្រមូលវិភាគ និងចងក្រងរក្សាទុករាល់ខ្លឹមសារ និងឯកសារដែលមានចរិតផ្សាភ្ជាប់នឹងលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត
- រៀបចំ និងចងក្រងរបាយការណ៍បូកសរុបលទ្ធផលសម្រាប់ការបញ្ចប់នីតិវិធីប្រឡងប្រណាំងទីក្រុងស្អាតមួយវគ្គៗ
- សហការជាមួយការិយាល័យជំនាញរៀបចំចងក្រងឯកសារពិគ្រោះផ្សេងៗ
- សហការរៀបចំគម្រោងគំរូនានាទាក់ទងនឹងចលនាប្រឡងប្រណាំងទីក្រុងស្អាត
- សហការជាមួយការិយាល័យពាក់ព័ន្ធ ក្នុងការរៀបចំកម្មវិធីគម្រោងអភិវឌ្ឍន៍ផ្សព្វផ្សាយកិច្ចប្រជុំសិក្ខាសាលា និងពិធីផ្សេងៗក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ។

**២-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ** មានតួនាទី និងភារកិច្ចៈ

- ពិនិត្យវិភាគលើពាក្យសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាតរបស់ខណ្ឌបេក្ខភាព នៃរាជធានីភ្នំពេញរួមមានៈ ខណ្ឌ៧មករា ខណ្ឌមានជ័យ ខណ្ឌឫស្សីកែវ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌដង្កោ ខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ និងខណ្ឌជ្រោយចង្វារ និងខណ្ឌផ្សេងៗទៀតនៃរាជធានីភ្នំពេញ
- ធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃសាកល្បងសម្រាប់ ខណ្ឌបេក្ខភាព
- ផ្តល់អនុសាសន៍ណែនាំដល់ខណ្ឌបេក្ខភាពអំពីចំនុចខ្លាំង និងចំនុចខ្សោយធៀបលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត និងផ្តល់យោបល់ដើម្បីចូលរួមលើកកម្ពស់លទ្ធភាពចូលរួមរបស់ខណ្ឌបេក្ខភាព
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងនៅតាមខណ្ឌបេក្ខភាពនីមួយៗ
- រៀបចំនិងដាក់ឱ្យដំណើរការគម្រោងកម្មវិធីអភិវឌ្ឍន៍ កម្មវិធីការងារដើម្បីជំរុញ និងចូលរួមជំរុញនិងលើកកម្ពស់លទ្ធភាពចូលរួមរបស់ខណ្ឌបេក្ខភាពក្នុងការសម្របសម្រួលទីក្រុងស្អាត
- តាមដានវាយតម្លៃនូវរាល់សកម្មភាព និងការអនុវត្តរបស់ខណ្ឌបេក្ខភាពអំពីផលប៉ះពាល់មកលើលក្ខណៈវិនិច្ឆ័យរបស់ស្តង់ដាទីក្រុងស្អាត និងធ្វើរបាយការណ៍បច្ចុប្បន្នភាពស្ថានភាពខណ្ឌបេក្ខភាព និងរបាយការណ៍អំពីករណីមិនប្រក្រតីរបស់ខណ្ឌបេក្ខភាព

- សិក្សាស្រាវជ្រាវប្រមូលវិភាគ និងរក្សាទុករាល់ឯកសារទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងស្អាតរបស់ខណ្ឌបេក្ខភាព ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាពខណ្ឌបេក្ខភាពធៀបនឹងស្តង់ដាទីក្រុងស្អាត
- ជំរុញលើកកម្ពស់សោភណ្ឌភាពទីប្រជុំជន និងគោលដៅទេសចរណ៍ក្នុងខណ្ឌនៃរាជធានីភ្នំពេញ
- ធ្វើទំនាក់ទំនងជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតរាជធានីភ្នំពេញ សម្រាប់ក្របខណ្ឌការងាររបស់ខ្លួនដូចមានកំណត់ក្នុងប្រការនេះ
- ធ្វើទំនាក់ទំនងផ្តល់ និងចែកចាយព័ត៌មានបន្តពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតទៅថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ថ្នាក់ខណ្ឌ និងប្រមូលត្រឡប់មកវិញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាត និងតាមដានអង្កេតក្រោយប្រកាសជ័យលាភីមួយលើកៗ
- ប្រមូលវិភាគចងក្រងជារបាយការណ៍ការងាររបស់ក្រុមការងារវាយតម្លៃទីក្រុងស្អាត និងរបាយការណ៍វឌ្ឍនភាពរបស់ខណ្ឌបេក្ខភាព
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ ក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ។

**៣-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគពាយ័ព្យ** មានតួនាទី និងភារកិច្ចៈ

- ពិនិត្យវិភាគលើពាក្យស្នើសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាតរបស់ក្រុងបេក្ខភាព នៅភាគពាយ័ព្យរួមមានៈ ក្រុងសៀមរាប ក្រុងបាត់ដំបង ក្រុងសេរីសោភ័ណ្ឌ ក្រុងប៉ោយប៉ែត ក្រុងប៉ៃលិន ក្រុងសំរោង ក្រុងព្រះវិហារ និងក្រុងពោធិ៍សាត់
- ធ្វើការវាយតម្លៃនិងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃសាកល្បងសម្រាប់ក្រុងបេក្ខភាពនីមួយៗ
- ផ្តល់អនុសាសន៍ណែនាំដល់ក្រុងបេក្ខភាពអំពីចំនុចខ្លាំង និងចំនុចខ្សោយធៀបលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត និងផ្តល់យោបល់ដើម្បីចូលរួមលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាព
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងទៅតាមក្រុងបេក្ខភាពនីមួយៗ
- រៀបចំ និងដាក់ឱ្យដំណើរការគម្រោងកម្មវិធីអភិវឌ្ឍន៍ កម្មវិធីការងារដើម្បីចូលរួមជំរុញ និងលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាពក្នុងការសម្របសម្រួលទីក្រុងស្អាត
- តាមដានវាយតម្លៃនូវរាល់សកម្មភាព និងការអនុវត្តរបស់ក្រុងបេក្ខភាពអំពីផលប៉ះពាល់មកលើលក្ខណៈវិនិច្ឆ័យរបស់ស្តង់ដាទីក្រុងស្អាត និងធ្វើរបាយការណ៍បច្ចុប្បន្នភាពស្ថានភាពក្រុងបេក្ខភាព និងរបាយការណ៍អំពីករណីមិនប្រក្រតីរបស់ក្រុងបេក្ខភាព
- សិក្សាស្រាវជ្រាវប្រមូលវិភាគនិងរក្សាទុករាល់ឯកសារទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងស្អាតរបស់ក្រុងបេក្ខភាព ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាពក្រុងបេក្ខភាព ធៀបនឹងស្តង់ដាទីក្រុងស្អាត
- ជំរុញលើកកម្ពស់សោភណ្ឌភាពទីប្រជុំជន និងគោលដៅទេសចរណ៍ក្នុងក្រុងបេក្ខភាព
- ធ្វើទំនាក់ទំនងជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់ខេត្ត សម្រាប់ក្របខណ្ឌការងាររបស់ខ្លួនដូចមានកំណត់ក្នុងប្រការនេះ
- ធ្វើទំនាក់ទំនងផ្តល់ និងចែកចាយព័ត៌មានបន្តពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ទៅថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់ក្រុង និងប្រមូលត្រឡប់មកវិញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាតនិងតាមដានអង្កេតក្រោយប្រកាសជ័យលាភីមួយលើកៗ
- ប្រមូលវិភាគ ចងក្រងជារបាយការណ៍ការងាររបស់ក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់ខេត្ត និងរបាយការណ៍វឌ្ឍនភាពរបស់ក្រុងបេក្ខភាព
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ ក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ។

**៤- ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគឦសាន្ត** មានតួនាទី និងភារកិច្ចៈ

- ពិនិត្យវិភាគលើពាក្យសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាតរបស់ក្រុងបេក្ខភាព នៅភាគឦសាន្ត រួមមានៈ ក្រុងបានលុង ក្រុងសែនមនោរម្យ ក្រុងក្រចេះ ក្រុងស្ទឹងត្រែង ក្រុងសួង ក្រុងកំពង់ចាម ក្រុងកំពង់ឆ្នាំង និងក្រុងស្ទឹងសែន
- វាយតម្លៃ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃសាកល្បងសម្រាប់ក្រុងបេក្ខភាពនីមួយៗ
- ផ្តល់អនុសាសន៍ណែនាំដល់ក្រុងបេក្ខភាពអំពីចំនុចខ្លាំង និងចំនុចខ្សោយ ធៀបលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត និងផ្តល់យោបល់ដើម្បីចូលរួមលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាព
- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងនៅតាមក្រុងបេក្ខភាពនីមួយៗ
- រៀបចំ និងដាក់ឱ្យដំណើរការគម្រោងកម្មវិធីអភិវឌ្ឍន៍កម្មវិធីការងារ ដើម្បីចូលរួមជំរុញ និងលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាពក្នុងការសម្របសម្រួលទីក្រុងស្អាត
- តាមដាន វាយតម្លៃនូវរាល់សកម្មភាព និងការអនុវត្តរបស់ក្រុងបេក្ខភាពអំពីផលប៉ះពាល់មកលើលក្ខណៈវិនិច្ឆ័យរបស់ស្តង់ដាទីក្រុងស្អាត និងធ្វើរបាយការណ៍បច្ចុប្បន្នភាពស្ថានភាពក្រុងបេក្ខភាព និងរបាយការណ៍អំពីករណីមិនប្រក្រតីរបស់ក្រុងបេក្ខភាព
- សិក្សាស្រាវជ្រាវ ប្រមូលវិភាគ និងរក្សាទុករាល់ឯកសារទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងស្អាតរបស់ក្រុងបេក្ខភាព ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាពក្រុងបេក្ខភាព ធៀបនឹងស្តង់ដាទីក្រុងស្អាត
- ជំរុញលើកកម្ពស់សោភណ្ឌភាពទីប្រជុំជន និងគោលដៅទេសចរណ៍ក្នុងក្រុងបេក្ខភាព
- ធ្វើទំនាក់ទំនងជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់ខេត្ត សម្រាប់ក្របខណ្ឌការងាររបស់ខ្លួនដូចមានកំណត់ក្នុងប្រការនេះ
- ធ្វើទំនាក់ទំនងផ្តល់ និងចែកចាយព័ត៌មានបន្តពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ទៅថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់ក្រុង និងប្រមូលត្រឡប់មកវិញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាត និងតាមដានអង្កេតក្រោយប្រកាសជ័យលាភីម្តងលើកៗ
- ប្រមូលវិភាគចងក្រងជារបាយការណ៍ការងារ របស់ក្រុមការងារវាយតម្លៃទីក្រុងស្អាត និងរបាយការណ៍វឌ្ឍនភាពរបស់ក្រុងបេក្ខភាព
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ ក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ។

**៥- ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងស្អាតភាគខាងត្បូង** មានតួនាទី និងភារកិច្ចៈ

- ពិនិត្យ វិភាគលើពាក្យសុំចូលរួមប្រឡងប្រណាំងទីក្រុងស្អាត របស់ក្រុងបេក្ខភាព ភាគខាងត្បូង រួមមានៈ ក្រុងកំពត ក្រុងព្រះសីហនុ ក្រុងកែប ក្រុងខេមរភូមិន្ទ ក្រុងតាខ្មៅ ក្រុងដូនកែវ ក្រុងព្រៃវែង ក្រុងបាវិត ក្រុងស្វាយរៀង និងក្រុងច្បារមន
- ធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃសាកល្បងសម្រាប់ក្រុងបេក្ខភាពនីមួយៗ
- ផ្តល់អនុសាសន៍ណែនាំដល់ក្រុងបេក្ខភាពអំពីចំនុចខ្លាំង និងចំនុចខ្សោយធៀបលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងស្អាត និងផ្តល់យោបល់ដើម្បីចូលរួមលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាព
- ចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងនៅតាមក្រុងបេក្ខភាពនីមួយៗ
- រៀបចំ និងដាក់ឱ្យដំណើរការគម្រោងកម្មវិធីអភិវឌ្ឍន៍ កម្មវិធីការងារដើម្បីចូលរួមជំរុញនិងលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុងបេក្ខភាពក្នុងការសម្របសម្រួលទីក្រុងស្អាត
- តាមដានវាយតម្លៃនូវរាល់សកម្មភាព និងការអនុវត្តរបស់ក្រុងបេក្ខភាពអំពីផលប៉ះពាល់មកលើលក្ខណៈវិនិច្ឆ័យរបស់ស្តង់ដាទីក្រុងស្អាត និងធ្វើរបាយការណ៍បច្ចុប្បន្នភាពស្ថានភាពក្រុងបេក្ខភាព និងរបាយការណ៍អំពីករណីមិនប្រក្រតីរបស់ក្រុងបេក្ខភាព

- សិក្សាស្រាវជ្រាវប្រមូលវិភាគ និងរក្សាទុករាល់ឯកសារទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងស្អាតរបស់ក្រុងបេក្ខភាព ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាពក្រុងបេក្ខភាពធៀបនឹងស្តង់ដាទីក្រុងស្អាត
- ជំរុញលើកកម្ពស់សោភណ្ឌភាពទីប្រជុំជន និងគោលដៅទេសចរណ៍ក្នុងក្រុងបេក្ខភាព
- ធ្វើទំនាក់ទំនងជាមួយក្រុមការងារវាយតម្លៃទីក្រុងស្អាតថ្នាក់ខេត្ត សម្រាប់ក្របខណ្ឌការងាររបស់ខ្លួនដូចមានកំណត់ក្នុងប្រការនេះ
- ធ្វើទំនាក់ទំនងផ្តល់ និងចែកចាយព័ត៌មានបន្តពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតទៅថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់ក្រុង និងប្រមូលត្រឡប់មកវិញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៃការប្រឡងប្រណាំងទីក្រុងស្អាត និងតាមដានអង្កេតក្រោយប្រកាសជ័យលាភីម្តងៗ
- ប្រមូលវិភាគចងក្រងជារបាយការណ៍ការងាររបស់ក្រុមការងារវាយតម្លៃទីក្រុងស្អាត និងរបាយការណ៍វឌ្ឍនភាពរបស់ក្រុងបេក្ខភាព
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗ ក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ។

**៦-ការិយាល័យបច្ចេកទេសវាយតម្លៃទីក្រុងទេសចរណ៍ស្អាតអាស៊ាន** មានតួនាទី និងភារកិច្ចៈ
- ពិនិត្យ វិភាគលើពាក្យសុំចូលរួមប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- ធ្វើការវាយតម្លៃ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃសាកល្បងសម្រាប់ក្រុង ខណ្ឌបេក្ខភាពនីមួយៗ
- ផ្តល់អនុសាសន៍ណែនាំដល់ក្រុង ខណ្ឌបេក្ខភាពអំពីចំនុចខ្លាំង និងចំនុចខ្សោយធៀបលក្ខណៈវិនិច្ឆ័យនៃស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងផ្តល់យោបល់ដើម្បីចូលរួមលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុង ខណ្ឌបេក្ខភាព
- ចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់ដល់ទីតាំងជាក់ស្តែងនៅតាមក្រុង ខណ្ឌបេក្ខភាពនីមួយៗ
- រៀបចំ និងដាក់ឱ្យដំណើរការគម្រោងកម្មវិធីអភិវឌ្ឍន៍ កម្មវិធីការងារដើម្បីចូលរួមជំរុញនិងលើកកម្ពស់លទ្ធភាពចូលរួមរបស់ក្រុង ខណ្ឌបេក្ខភាពក្នុងការសម្របសម្រួលទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- តាមដានវាយតម្លៃនូវរាល់សកម្មភាព និងការអនុវត្តរបស់ក្រុង ខណ្ឌបេក្ខភាពអំពីផលប៉ះពាល់មកលើលក្ខណៈវិនិច្ឆ័យរបស់ស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងធ្វើរបាយការណ៍បច្ចុប្បន្នភាពស្ថានភាពក្រុង ខណ្ឌបេក្ខភាព និងរបាយការណ៍អំពីករណីមិនប្រក្រតីរបស់ក្រុង ខណ្ឌបេក្ខភាព
- សិក្សាស្រាវជ្រាវប្រមូលវិភាគ និងរក្សាទុករាល់ឯកសារទិន្នន័យដែលពាក់ព័ន្ធនឹងការប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ានរបស់ក្រុង ខណ្ឌបេក្ខភាព ដើម្បីចងក្រងជាសៀវភៅវឌ្ឍនភាពក្រុង ខណ្ឌបេក្ខភាពធៀបនឹងស្តង់ដាទីក្រុងទេសចរណ៍ស្អាតអាស៊ាន
- ធ្វើទំនាក់ទំនងផ្តល់ និងចែកចាយព័ត៌មានបន្តពីគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតទៅថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់ក្រុង និងប្រមូលត្រឡប់មកវិញនូវរាល់ទិន្នន័យដែលពាក់ព័ន្ធនឹងដំណើរការនីតិវិធីនៃការប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងតាមដានអង្កេតក្រោយប្រកាសជ័យលាភីម្តងៗ
- ប្រមូល វិភាគ ចងក្រងជារបាយការណ៍ការងាររបស់ក្រុមការងារវាយតម្លៃទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងរបាយការណ៍វឌ្ឍនភាពរបស់ក្រុង ខណ្ឌបេក្ខភាព
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ស្តីពីការជម្រុញចលនាប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតថ្នាក់អាស៊ាន
- ធ្វើទំនាក់ទំនងជាមួយប្រទេសសមាជិកអាស៊ាន លើរាល់សកម្មភាពទាក់ទងនឹងការប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន

- ធ្វើទំនាក់ទំនង ផ្តល់ និងចែកចាយព័ត៌មានបន្តពីថ្នាក់តំបន់-អាស៊ាន ទៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាបេក្ខភាពប្រឡងប្រណាំង អំពីបច្ចុប្បន្នភាពនានា
- សហការជាមួយអង្គភាព និងផ្នែកពាក់ព័ន្ធក្នុងការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗក្នុងក្របខណ្ឌការងាររបស់ខ្លួនដូចមានចែងក្នុងប្រការនេះ
- សហការ ជំរុញ ធ្វើទំនាក់ទំនង និងពង្រឹងសមត្ថភាពបេក្ខភាពទីក្រុងទេសចរណ៍ស្អាតអាស៊ានទាំងអស់ សំដៅទទួលបានជ័យលាភីថ្នាក់អាស៊ាន។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានវាយតម្លៃទីក្រុងស្អាត មានតួនាទី និងភារកិច្ចៈ

- ធ្វើកំណត់ហេតុប្រជុំដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ខ្លួន
- រៀបចំផែនការសកម្មភាពការងារ និងថវិកាចំណាយផ្សេងៗ និងប្រចាំឆ្នាំជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានវាយតម្លៃទីក្រុងស្អាត ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ